# សេចក្តីថ្លែងការណ៍ជាខ្សែវីដេអូរបស់ឧត្តមស្នងការសិទ្ធិមនុស្ស
# នាឱកាសទិវាសិទ្ធិមនុស្សឆ្នាំ២០១៦

ព្រឹត្តិការណ៍ថ្ងៃនេះនៅលើពិភពលោក ធ្វើឲ្យមនុស្សជាច្រើនក្នុងចំណោមយើងគ្រប់រូប មានការអន្ទះសារផង មានការភ័យខ្លាចផង។ យើងមើលឃើញមនុស្សជាតិកំពុងទទួលរងការឈឺចាប់។ គុណតម្លៃស្របតាមបទដ្ឋានសីលធម៌ដែលសង្គមទទួលយក កំពុងស្ថិតក្រោមការវាយប្រហារ។ សារនានាបញ្ជាក់ពីការខឹងស្អប់ និងការមិនចះអត់ឱនឲ្យគ្នា ទស្សនៈបំបែកបំបាក់គ្នាក្នុងពិភពលោក ដែលរុញច្រានទៅរកភាពអាត្មានិយមកាន់តែខ្លាំងឡើង។ ការផាត់ចេញ។ ទង្វើខុសឆ្គងហើយទម្លាក់កំហុសឲ្យអ្នកដទៃ។ អំពើហិង្សា។

ហើយនៅក្នុងរលកបំពុលដោយការខឹងស្អប់នេះ ដែលបាន និងកំពុងកើនឡើងសន្សឹមៗនៅក្នុងសង្គមជាច្រើននោះ គោលការណ៍ស៊ីជម្រៅ សំខាន់បំផុតនានា ដែលធានាការពារមិនឲ្យកើតមានហានិភ័យដល់សង្គមសន្តិភាព បាន និងកំពុងត្រូវគេសម្អាតចេញទៅហើយ។

យើងចាំបាច់ត្រូវបញ្ឈប់រលកបំពុលដោយការខឹងស្អប់នេះ។ ហើយខ្ញុំជឿជាក់ថាយើងអាចធ្វើបាន។ យើង ដែលមានអ្នកទាំងអស់គ្នានិងខ្ញុំ អាចកំណត់ព្រំដែនដើម្បីបញ្ឈប់បញ្ហានេះ។

យើងមិនត្រូវនៅស្ងៀមមិនធ្វើអ្វីសោះឡើយ នៅពេលដែលការខឹងស្អប់បង្កឲ្យមានអរិភាពរវាងសហគមន៍ផ្សេងៗនោះ។ យើងអាចព្យាយាមបង្កើតទំនាក់ទំនងល្អរវាងសហគមន៍ទាំងនោះ។ យើងអាចលើកជាមតិយោបល់របស់យើងបាន។

យើងអាចក្រោកឈរឡើង ដើម្បីគុណតម្លៃសង្គមដែលស្របតាមបទដ្ឋានសីលធម៌ មានមេត្តាករុណា។

នៅពេលដែលនរណាម្នាក់ត្រូវគេរំលោភបំពាន និងមានការភ័យខ្លាច យើងអាចចូលទៅជួយធានាការពារសិទ្ធិរបស់គាត់។ នៅពេលដែលជនងាយរងគ្រោះម្នាក់ត្រូវគេសម្លុតធ្វើបាប យើងអាចចូលរួមបញ្ឈប់ការសម្លុតធ្វើបាបនោះ។ នៅទីណាកន្លែងណាដែលមានការរើសអើង និងការកេងប្រវ័ញ្ច យើងអាចសម្តែងមតិយោបល់ និងបង្ហាញឲ្យគេបានដឹងថា យើងប្រឆាំងនឹងការរើសអើង និងការកេងប្រវ័ញ្ចនេះ និងស្នើសុំឲ្យបញ្ឈប់វា។ យើងអាចចូលរួមជាមួយអ្នកដទៃដើម្បីផ្សព្វផ្សាយជាសាធារណៈដើម្បីឲ្យមានការដឹកនាំកាន់តែល្អ ច្បាប់កាន់តែប្រសើរ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សកាន់តែមុតមាំថែមទៀត។

នៅតាមដងផ្លូវ។ នៅក្នុងសាលារៀន។ នៅកន្លែងធ្វើការ។ នៅកន្លែងដឹកជញ្ជូនសាធារណៈ។ នៅក្នុងបន្ទប់បោះឆ្នោត។ នៅតាមផ្ទះសម្បែង។ នៅតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។ នៅទីលានលេងកីឡា។ នៅទីណាកន្លែងណាក៏ដោយ

យើងអាចធ្វើឱ្យមានការផ្លាស់ប្តូរពិតប្រាកដក្នុងឆាកជីវិតរបស់បុគ្គលម្នាក់មែន ប៉ុន្តែប្រហែលជាអាចផ្លាស់ប្តូរឆាកជីវិតរបស់បុគ្គលជាច្រើននាក់ទៀតក៏អាចថាបាន។

ជំហានក្នុងស្រុកធ្វើឲ្យមានចលនាសកល។ វាផ្តើមចេញពីយើងទាំងអស់គ្នាក្នុងការបោះជំហានបំពេញការងារជាក់ស្តែងដើម្បីបញ្ជាក់ជាថ្មីឡើងវិញអំពីជំនឿរបស់យើងទៅលើមនុស្សជាតិ និងសមភាព។

ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ធ្វើការដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅជុំវិញពិភពលោក។ យើងបំពេញការងារសម្រាប់ពិភពលោកមួយដែលបង្កើតឡើងដោយ "យើងទាំងអស់គ្នាជាមនុស្ស" ដូចមានចែងក្នុងធម្មនុញ្ញ អ.ស.ប។ ពិភពលោកដែលមានយុត្តិធម៌ សមភាព និងសិទ្ធមនុស្ស។

សូមចូលរួមដើម្បីបុព្វហេតុរបស់យើង។ សូមប្រាប់យើងឲ្យបានដឹងពីការងារអ្វីខ្លះដែលអ្នកកំពុងធ្វើ ហើយយើងនឹងប្រមូលចងក្រងរឿងរ៉ាវរបស់អ្នក ហើយធ្វើឲ្យគេឮកាន់តែខ្លាំងនូវមតិយោបល់របស់អ្នក។

វាត្រូវផ្តើមចេញពីយើងម្នាក់ៗ។

សូមក្រោកឈរឡើងដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។

**ចប់**